ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៦៣ អនក្រ បក

# អនុក្រឹត្យ

## ស្តីពី

## ការគ្រប់គ្រង ក្រុមពិនិត្យសិល្បៈភាពយន្ត និង វីដេអូ

ចុះថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ ២០០០

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ ៦៣ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការគ្រប់គ្រង ត្រួតពិនិត្យសិល្បៈភាពយន្ត និង វីដេអូ

### រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០២ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតក្រសួង វប្បធម៌ និងវិចិត្រសិល្បៈ

-បានឃើញអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង វប្បធម៌ និងវិចិត្រសិល្បៈ

-បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងកិច្ចប្រជុំពេញអង្គនាថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០០០

### ស ម្រ េ ច

### ជំពូកទី១

### បទប្បញ្ញត្តិទូទៅ

មាត្រា១. -

អនុក្រឹត្យនេះមានគោលបំណងគ្រប់គ្រង ត្រួតពិនិត្យសិល្បៈភាពយន្ត វីដេអូ ព្រមទាំងផ្តល់ការលើកទឹកចិត្តផលិតកម្មភាពយន្ត និង វីដេអូក្នុងប្រទេសដើម្បី ថែរក្សា ការពារវប្បធម៌ជាតិ ជានាដល់ការគោរពសីលធម៌សង្គម ។

មាត្រា២. -

ការគ្រប់គ្រង និងការបង្ក្រាបបទល្មើសភាពយន្ត វីដេអូ សំដៅលើការត្រួតពិនិត្យការផលិតផ្សព្វផ្សាយ ត្រួតពិនិត្យការធ្វើអាជីវកម្មតាមគ្រប់មធ្យោបាយនូវ សិល្បៈទី៧ មានស្នាដៃភាពយន្ត និង ស្នាដៃវីដេអូដែលមានទម្រង់ផ្សេងៗដូចជា ខ្សែភាពយន្ត កាស្សែតវីដេអូ ឡាហ្ស៊ែរឌីស ស៊ីឌីវីដេអូ ឌីវីឌី ស៊ីឌីរ៉ម ។

## ជំពូកទី២

## អំពីនិយមន័យ

មាត្រា៣. -

និយមន័យទាំងឡាយចែងក្នុងអនុក្រឹត្យនេះ មានតម្លៃសំរាប់ប្រើប្រាស់តែក្នុងអនុក្រឹត្យនេះប៉ុណ្ណោះ

មាត្រា៤. -

ស្នាដៃគឺជាការបង្កើតថ្មីទាំងអស់របស់បញ្ញា ។

មាត្រា៥. -

ស្នាដៃភាពយន្តគឺជា ខ្លឹមសារ រូបភាព សំឡេងដែលស្ថិតក្នុង :

ក : - ខ្សែភាពយន្តរឿង : ខ្នាតវែង ខ្លី ភាគ

ខ : - ខ្សែភាពយន្តឯកសារស្តីពី រមណីយដ្ឋានវប្បធម៌ : ខ្នាតវែង ខ្លី

គ : - ខ្សែភាពយន្តឯកសារពាក់ព័ន្ធដល់ប្រពៃណីជាតិ : ខ្នាតវែង ខ្លី

ឃ : - ខ្សែភាពយន្តគំនូរជីវចល

មាត្រា៦. -

ខ្សែភាពយន្តខ្នាតវែង ជាខ្សែភាពយន្តដែលមានរយៈពេលបញ្ចាំងចាប់ពី ៦០នាទីឡើងទៅ ។

មាត្រា៧. -

ខ្សែភាពយន្តខ្នាតខ្លី ជាខ្សែភាពយន្តដែលមានរយៈពេលបញ្ចាំងតិចជាង ៦០នាទី ។

មាត្រា៨. -

ខ្សែភាពយន្តភាគ ជាខ្សែភាពយន្តដែលមានដំណើររឿងចែកជាវគ្គខ្លីៗ ។

មាត្រា៩. -

ស្នាដៃវីដេអូគឺជា : វីដេអូរឿងវែង ខ្លី ភាគ វីដេអូខារ៉ាអូខេ វីដេអូចម្រៀងកាយវិការ វីដេអូគំនូរជីវចល វីដេអូឯកសារស្តីពីរមណីយដ្ឋានវប្បធម៌ និងវីដេអូឯកសារដែលពាក់ព័ន្ធដល់ប្រពៃណីជាតិ ។

មាត្រា១០. -

-ទីវីដេអូ "គុណនាម" សំណុំបច្ចេកទេសដែលពាក់ព័ន្ធដល់ការបង្កើត ការផលិតបញ្ចូល ប្រព្រឹត្តកម្ម ការរក្សាទុក ការបញ្ជូនរូបភាព ឬ សញ្ញាប្រភេទទូរទស្សន៍ ។

- ទីវីដេអូ "នាម" ១ : សំណុំបច្ចេកទេសវីដេអូទាំងឡាយ ។

២ : ស្នាដៃទាំងឡាយដែលផលិតជាវីដេអូ ។

មាត្រា១១. -

ខារ៉ាអូខេជាពាក្យជប៉ុន ។ "ខារ៉ា = ទំនេរ អូខេ = តន្ត្រី" វីដេអូខារ៉ាអូខេគឺជាវីដេអូតន្ត្រីសំរាប់អ្នកទស្សនាអាចច្រៀងតាមបាន ។

## ជំពូកទី៣

## អំពីអាជ្ញាប័ណ្ណធ្វើផលិតកម្ម ស្នាដៃភាពយន្ត និង ស្នាដៃវីដេអូ

មាត្រា១២. -

ក្រុមហ៊ុនផលិតកម្ម ឬ រូបវន្តបុគ្គលដែលមានបំណងធ្វើផលិតកម្មភាពយន្ត ឬ ផលិតកម្មវីដេអូ ក្នុងប្រទេស ដើម្បីផលិតចេញជាស្នាដៃភាពយន្ត និង ស្នាដៃវីដេអូ សំរាប់ធ្វើអាជីវកម្មផ្សព្វផ្សាយទាំងក្នុងនិងក្រៅប្រទេស ត្រូវសុំអាជ្ញាប័ណ្ណពីក្រសួង វប្បធម៌ និង វិចិត្រសិល្បៈ ក្រោយពីការចុះបញ្ជីពាណិជ្ជកម្មនៅ ក្រសួងពាណិជ្ជកម្មរួច ។

មាត្រា១៣. -

មុននឹងអនុញ្ញាតឱ្យធ្វើអាជីវកម្មតាមគ្រប់មធ្យោបាយ ក្រុមហ៊ុនផលិតកម្មទាំងអស់ ទាំងក្នុងស្រុកទាំងបរទេស ដែលមានបំណងផលិតស្នាដៃភាពយន្ត និង ស្នាដៃវីដេអូ ត្រូវយកអត្ថបទរឿងពិស្តារជាអក្សរសិល្ប៍ភាសាជាតិ មានពាក្យសន្ទនា ទំនុកច្រៀង ឬអត្ថបទសង្ខេបឯកសារទៅដាក់ជូន ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈពិនិត្យនិងយល់ព្រមជាមុនសិន ដើម្បីផ្តល់លិខិតអនុញ្ញាតឱ្យផលិតក្នុងរយៈពេល ១៥ ថ្ងៃ យ៉ាងយូរ បន្ទាប់ពីដាក់ពាក្យស្នើសុំ បើហួសកំណត់នេះ ត្រូវចាត់ទុកថាបានយល់ព្រម ។

ចំពោះក្រុមហ៊ុនបរទេសត្រូវភ្ជាប់ជាមួយផងដែរ នូវច្បាប់បង្កើតក្រុមហ៊ុនរបស់ខ្លួន ។

មាត្រា១៤. -

កិច្ចសហការជាមួយក្រុមហ៊ុនផលិតកម្មបរទេស ជនបរទេស ឬពលរដ្ឋកម្ពុជា ដែលរស់នៅបរទេសមានបំណងមកផលិតស្នាដៃភាពយន្ត និងស្នាដៃវីដេអូ នៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ជាភារកិច្ចរបស់ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ និង ក្រសួង ពត៌មាន ។

មាត្រា១៥. -

ការចេញអាជ្ញាប័ណ្ណដូចមានចែងក្នុងមាត្រា ១២ ការពិនិត្យ និងផ្តល់ការយល់ព្រមក្នុងមាត្រា ១៣ និង ការអនុញ្ញាតិឱ្យចូលមកថតខ្សែភាពយន្ត ឬ វីដេអូក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវបង់កំរៃ អាជ្ញាប័ណ្ណ និង កំរៃរដ្ឋបាលជូនក្រសួងវប្បធម៌និងវិចិត្រសិល្បៈដែលកំណត់ដោយប្រកាសរួមរបស់ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ និង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

## ជំពូកទី៤

## អំពីការធ្វើអាជីវកម្មស្នាដៃភាពយន្ត និង ស្នាដៃវីដេអូ

មាត្រា១៦. -

ការប្រកបមុខរបរធ្វើអាជីវកម្មស្នាដៃភាពយន្ត និងស្នាដៃវីដេអូរួមមាន : ការបើកអាជីវកម្មនាំចេញ - នាំចូល ចែកបញ្ចាំង ថតចម្លង បញ្ចូលសំឡេង កាត់ត ដំឡើងភាពយន្ត ឬវីដេអូសំរាប់ធ្វើអាជីវកម្ម ត្រូវមាន ការអនុញ្ញាតពីក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ ។

មាត្រា១៧. -

ការបើករោងបញ្ចាំងភាពយន្ត ឬរោងបញ្ចាំងវីដេអូ ត្រូវមានការអនុញ្ញាតពី ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ ដោយបំពេញល័ក្ខខ័ណ្ឌដូចខាងក្រោម :

ក - អំពីបទដ្ឋានសន្តិសុខ : រៀបចំលក្ខណៈអគ្គិភ័យ និងការជ្រួលច្របល់ផ្សេងៗសមស្រប តាមការកំណត់របស់ក្រសួងមហាផ្ទៃ ។

ខ - អំពីបទដ្ឋានបច្ចេកទេស : ទំហំផ្ទាំងសំពត់ស ការរៀបចំកន្លែងសំរាប់ទស្សនិកជន ការរៀបចំបន្ទប់បញ្ចាំង សមស្របតាមការកំណត់របស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ។

## ជំពូកទី៥

## អំពីការពិនិត្យខ្លឹមសារ និងផ្តល់និទ្ទេសការស្នាដៃភាពយន្ត និង ស្នាដៃវីដេអូ

មាត្រា១៨. -

ការពិនិត្យខ្លឹមសារនៃស្នាដៃភាពយន្ត និង ស្នាដៃវីដេអូ ជាសមត្ថកិច្ចរបស់ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ ។

ក្នុងករណីចាំបាច់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ អាចអញ្ជើញតំណាងក្រសួងស្ថាប័នពាក់ព័ន្ធ ដើម្បី ចូលរួមពិនិត្យ និង សម្រេច ។

មាត្រា១៩.-

ការផ្តល់ទិដ្ឋាការឱ្យស្នាដៃភាពយន្ត ឬវីដេអូ សំរាប់យកទៅធ្វើអាជីវកម្ម ចាក់បញ្ចាំង ឬផ្សព្វផ្សាយជាសាធារណៈតាមគ្រប់មធ្យោបាយ ជាភារកិច្ចរបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ។

មាត្រា២០.-

ស្នាដៃភាពយន្ត និង ស្នាដៃវីដេអូតាមទម្រង់ដូចមានចែងក្នុងមាត្រា ២ ខាងលើ មុននឹងយកទៅធ្វើអាជីវកម្ម ជួល លក់ ចាក់បញ្ចាំង ផ្សព្វផ្សាយជាសាធារណៈតាមគ្រប់មធ្យោបាយ ឬ នាំចេញទៅក្រៅប្រទេសត្រូវមានទិដ្ឋាការអនុញ្ញាតពីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ។

ល័ក្ខខ័ណ្ឌនៃការសុំទិដ្ឋាការអនុញ្ញាតសំរាប់ ស្នាដៃភាពយន្ត និង ស្នាដៃវីដេអូ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ។

## ជំពូកទី៦

## អំពីការត្រួតពិនិត្យ និងបង្ក្រាបបទល្មើសក្នុងសកម្មភាព ផលិត ធ្វើអាជីវកម្ម និងផ្សព្វផ្សាយ ស្នាដៃភាពយន្ត និង ស្នាដៃវីដេអូ

មាត្រា២១.-

ការធ្វើអាជីវកម្ម ជួល ឬលក់ កាសែ្សតវីដេអូ ឡាស៊ែរឌីស ស៊ីឌីវីដេអូ ឌីវីឌី និងការធ្វើអាជីវកម្មខារ៉ាអូខេ ត្រូវមានការត្រួតពិនិត្យពីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ។

មាត្រា២២.-

ការត្រួតពិនិត្យ និងបង្ក្រាបបទល្មើសក្នុងសកម្មភាពធ្វើអាជីវកម្ម និងផ្សព្វផ្សាយស្នាដៃភាពយន្ត ឬស្នាដៃវីដេអូដូចមានចែងក្នុងមាត្រា ១២ .១៣ និង ១៤ រួមទាំងការប្រកបមុខរបរដូចមានចែងក្នុងមាត្រា ១៦. និង ១៧ ជាសមត្ថកិច្ចរបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ។

ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ ត្រូវសុំបង្កើតគណៈកម្មការអន្តរក្រសួងមួយ ដើម្បីសហការត្រួតពិនិត្យ ឬបង្ក្រាប ដែលកំណត់ដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល ។

មាត្រា២៣:

មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្ត ក្រុង និង ការិយាល័យវប្បធម៌ និងវិចិត្រសិល្បៈ ខណ្ឌ ស្រុក និមួយៗ មានភារៈកិច្ចត្រួតពិនិត្យ និង បង្ក្រាបសកម្មភាពផលិត ធ្វើអាជីវកម្ម និងផ្សព្វផ្សាយស្នាដៃភាពយន្ត និង ស្នាដៃវីដេអូដោយសហការជាមួយអាជ្ញាធរដែនដី ខេត្ត ក្រុង និង ខណ្ឌ ស្រុករបស់ខ្លួន ។

# ជំពូកទី៧

## ទោសប្បញ្ញត្តិ

**មាត្រា២៤.-**

ត្រូវផ្អាកសកម្មភាព និង ពិន័យជាប្រាក់ពី ប្រាំមួយម៉ឺនរៀល (៦០.០០០រ០០) ទៅ ពីរសែនរៀល (២០០.០០០រៀល) ចំពោះជនណាដែលប្រព្រឹត្តល្មើសនឹងមាត្រា ១២ . ១៣ . ១៤ . ១៦ និង ១៧ នៃអនុក្រឹត្យនេះ ។

**មាត្រា២៥.-**

ជនណាដែលយកស្នាដៃភាពយន្ត និង ស្នាដៃវីដេអូគ្មានទិដ្ឋាការអនុញ្ញាតពីក្រសួង វប្បធម៌ និង វិចិត្រសិល្បៈទៅដាក់តាំង ជួល លក់ ត្រូវពិន័យជាប្រាក់តាម ល័ក្ខខ័ណ្ឌដូចខាងក្រោម ៖

១ - ពិន័យជាប្រាក់ពីប្រាំពីរពាន់ប្រាំរយរៀល( ៧.៥០០រ០០) ទៅប្រាំមួយម៉ឺនរៀល(៦០.០០០រ០០) សំរាប់កាសែ្សតវីដេអូមួយដុំ ឡាហ្សែរឌីស ស៊ីឌីវីដេអូ ឌីវីឌី និង ស៊ីឌីរ៉ូមមួយ ។

២- ពិន័យជាប្រាក់ពីពីរសែនរៀល (២០០.០០០រ០០) ទៅ ពីរលានរៀល (២.០០០.០០០រ០០) ចំពោះខ្សែភាពយន្តខ្នាតវែង មួយរឿង ។

**មាត្រា២៦.-**

ជនណាយកស្នាដៃភាពយន្ត និង ស្នាដៃវីដេអូគ្មានទិដ្ឋាការពីក្រសួងវប្បធម៌និងវិចិត្រសិល្បៈនាំចេញទៅក្រៅប្រទេសដើម្បីធ្វើអាជីវកម្មត្រូវដកហូត និង ពិន័យជាប្រាក់ ពី ពីរសែនរៀល (២០០.០០០រ០០) ទៅ ពីរលានរៀល(២.០០០.០០០រ០០)សំរាប់កាសែ្សតវីដេអូមួយដុំ ឡាហ្សែរឌីស ស៊ីឌីវីដេអូ ឌីវីឌី ស៊ីឌីរ៉ូមមួយ ឬ ខ្សែភាពយន្តខ្នាតវែងមួយរឿង លើកលែងតែភាពយន្ត និងវីដេអូមានលក្ខណៈជាគ្រួសារដែលមិនតម្រូវឱ្យមានទិដ្ឋាការពីក្រសួង វប្បធម៌ និង វិចិត្រសិល្បៈឡើយ ។

**មាត្រា២៧.-**

ជនណាយកស្នាដៃភាពយន្ត និង ស្នាដៃវីដេអូគ្មានទិដ្ឋាការទៅផ្សព្វផ្សាយជាសាធារណៈ តាមគ្រប់មធ្យោបាយត្រូវពិន័យជាប្រាក់ពី ប្រាំមួយម៉ឺនរៀល( ៦០.០០០រ០០) ទៅ ពីរសែនរៀល (២០០.០០០រ០០)។

មាត្រា២៨.-

ជនណាបញ្ចាំង កាត់ ត ដំឡើងរូបភាព ថតចម្លង ថតបញ្ចូលសម្លេង ជួល លក់ និង ចែកចាយ សំរាប់ធ្វើអាជីវកម្មនូវផលិតផលភាពយន្ត ឬ វីដេអូដែលមានលក្ខណៈរូបភាពអាសអាភាស ត្រូវពិន័យជាប្រាក់ពី ពីរសែនរៀល (២០០.០០០៛០០) ទៅ ពីរលានរៀល (២.០០០.០០០៛០០) ហើយដកហូតទាំងឧបករណ៍ សំភារៈភាពយន្ត ឬ វីដេអូក្នុងការធ្វើអាជីវកម្មនោះ ។ ដោយឡែក ខ្សែភាពយន្តឬកាសែ្សតវីដេអូ ឡាហ្វែរឌីស ស៊ីឌីវីដេអូ ឌីវីឌី ស៊ីឌីរ៉ម ត្រូវបំផ្លាញចោល ។

មាត្រា២៩.-

ចារី និង សហចារី ក្នុងការផលិតស្នាដៃភាពយន្ត ឬ វីដេអូអាសអាភាស ត្រូវដកហូតឧបករណ៍ សំភារៈ ហើយកសាងសំណុំរឿងបញ្ជូនទៅតុលាការ ។

មាត្រា៣០.-

ជនណាធ្វើការក្លែងបន្លំ លិខិតអនុញ្ញាត អាជ្ញាប័ណ្ណ ទិដ្ឋាការ បន្ថែមរូបភាព បញ្ចូលពាក្យសន្ទនា ឬ បញ្ចូលបទអត្ថាធិប្បាយទៅក្នុង ស្នាដៃភាពយន្ត ឬវីដេអូ ផ្ទុយពីច្បាប់ដើម ដែលក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ បានអនុញ្ញាតជាផ្លូវការរួចហើយ ត្រូវកសាងសំណុំរឿងបញ្ជូនទៅតុលាការ ។

មាត្រា៣១.-

ជនណាយកផលិតផលភាពយន្ត ឬ វីដេអូរបស់ក្រុមហ៊ុនណាមួយ ដែលក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ បានផ្តល់ទិដ្ឋាការរួចហើយ ទៅលួចចម្លងដើម្បីធ្វើអាជីវកម្ម ចាក់បញ្ចាំង ឬផ្សព្វផ្សាយជាសាធារណៈ តាមគ្រប់មធ្យោបាយ ធ្វើឱ្យប៉ះពាល់ផលប្រយោជន៍អ្នកដទៃ ត្រូវកសាងសំណុំរឿងបញ្ជូនទៅតុលាការ ។

មាត្រា៣២.-

ការពិន័យជាប្រាក់ដូចមានចែងក្នុងមាត្រា ២៤ ,២៥ , ២៦ ,២៧ និង ២៨ នៃអនុក្រឹត្រនេះ នឹងត្រូវ បង្កើនទ្វេឡើង ឬ បិទឈប់ឱ្យធ្វើអាជីវកម្មជាស្ថាពរកាលណាជនល្មើសនៅតែប្រព្រឹត្តល្មើសបន្តទៀត ។

មាត្រា៣៣.-

មន្ត្រីរាជការទាំងឡាយ ដែលមានភារៈកិច្ចពិនិត្យខ្លឹមសារនៃស្នាដៃភាពយន្ត ឬវីដេអូ និងត្រួតពិនិត្យ ឬបង្ក្រាបបទល្មើសភាពយន្ត វីដេអូ មានការឃុបឃិតឬប្រព្រឹត្តរំលោភភារកិច្ចរបស់ខ្លួនផ្ទុយពីបញ្ញត្តិទាំងឡាយ ដែលមានចែងក្នុងអនុក្រឹត្យនេះត្រូវទទួលទោសតាមបទបញ្ញត្តិច្បាប់សហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល ។

មាត្រា៣៤. –

ប្រាក់កំរៃអាជ្ញាប័ណ្ណ និង កំរៃរដ្ឋបាល ដូចមានចែងក្នុងមាត្រា ១២ និង ១៣ ត្រូវបង់ចូលថវិការដ្ឋទាំងអស់ ។

ប្រាក់ពិន័យដូចមានចែងក្នុងមាត្រា ២៤ .២៥. ២៦. ២៧ និង ២៨ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ត្រូវបានទទួលចំណែក ៤០ % សំរាប់ប្រើប្រាស់ជាផលប្រយោជន៍ដល់វិស័យសិល្បៈនិងវប្បធម៌ ។

ខ្ទង់ប្រាក់ចំណូលពីការផាកពិន័យទាំងអស់ ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ត្រូវអនុវត្តកាតព្វកិច្ចបង់ចូលថវិការដ្ឋ តាមមាត្រា ១១ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ជាមុនសិន ។រីឯចំណែក ៤០ % ត្រូវលើកសំណើសុំចំណាយវិញ ដោយផ្អែកសាលាកប័ត្របង់ប្រាក់ ឬ ប័ណ្ណបង្វែរគណនី ជាសក្ខីភាពថា ពិតជាបានបង់ចូលថវិការដ្ឋរួចហើយ ។

## ជំពូកទី៨

## អន្តរប្បញ្ញត្តិ

មាត្រា៣៥. –

គ្រប់ក្រុមហ៊ុននាំចេញ នាំចូល និង អាជីវករទាំងអស់ ដែលយកស្នាដៃភាពយន្ត ឬ ស្នាដៃវីដេអូ គ្មានទិដ្ឋាការអនុញ្ញាតពីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ទៅជួល លក់ ចាក់បញ្ចាំង ផ្សព្វផ្សាយជាសាធារណៈ តាមគ្រប់មធ្យោបាយ ត្រូវរូតរះយកស្នាដៃភាពយន្ត ឬ ស្នាដៃវីដេអូទាំងនោះទៅសុំទិដ្ឋាការពីក្រសួង វប្បធម៌ និង វិចិត្រសិល្បៈ ចាប់ពីពេលអនុក្រឹត្យនេះចូលជាធរមានរហូតដល់ថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០០១ ។

## ជំពូកទី៩

## អ វ សា ន ប្ប ញ្ញ ត្តិ

មាត្រា៣៦. –

អនុក្រឹត្យលេខ ៣២ អនក្រ ចុះថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ១៩៨៩ ស្តីពី ការគ្រប់គ្រង ត្រួតពិនិត្យភាពយន្ត និងវីដេអូរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី និងបទបញ្ញត្តិទាំងឡាយណាដែល ផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា១៧.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកអភិបាលរាជធានីភ្នំពេញ និងអភិបាលខេត្ត ក្រុងទាំងអស់ ដែលមានការពាក់ព័ន្ធ ត្រូវទទួលបន្ទុករៀងៗខ្លួនអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះ ហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

បានយកសេចក្តីជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រី ដើម្បីសុំហត្ថលេខា

រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ

នរោត្តម បុប្ផាទេវី

**កន្លែងទទួល**

- ខុទ្ទកាល័យព្រះមហាក្សត្រ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទការល័យនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ
- គ្រប់សាលាខេត្ត ក្រុង
- គ្រប់តុលាការខេត្ត ក្រុង
- ឯកសារ កាលប្បវត្តិ